# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** ...០០១/១៦...............**ក.ប/**សន.វប

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦

**ជម្រាបមក**
**លោកប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** ស្តីពីករណីលោក ស្រី ចំរើន និងកញ្ញា ធី សុវណ្ណថា ប្រតិបត្តិការការងារមួយចំនួនដោយអះអាងថាខ្លួនតំណាងសហជីព។

**យោង៖** លិខិតលេខ១៦៩/១៦ សសកពក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ របស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោកប្រធាន ជ្រាបថា ក្រសួងបានទទួលរួចហើយនូវលិខិតរបស់លោក ដែលស្នើសុំឱ្យក្រសួងពិនិត្យមើល និងមានវិធានការផ្លូវច្បាប់ទៅលើសកម្មភាពរបស់លោក ស្រី ចំរើន និងកញ្ញា ធី សុវណ្ណថា ដែលអះអាងថា ខ្លួនជាតំណាងសហជីព។ ក្រសួងសូមបញ្ជាក់ជូនថា ក្រសួងបានចេញលិខិតព្រមានដល់លោក ស្រី ចំរើន និងកញ្ញា ធី សុវណ្ណថា រួចហើយឱ្យបញ្ឈប់រាល់សកម្មភាពសហជីពដោយមិនបានចុះបញ្ជីជាបន្ទាន់ (ដូចមានលិខិតជូនភ្ជាប់)។ ក្នុងករណីនៅតែបន្តសកម្មភាពទៀត ក្រសួងនឹងអាចចាត់វិធានការដំណាក់កាលទី២ អនុលោមតាមច្បាប់ស្តីពីសហជីព។

អាស្រ័យហេតុនេះ សូម លោកប្រធាន ជ្រាបតាមការគួរ។

សូម លោកប្រធាន ទទួលនូវការរាប់អាន អំពីខ្ញុំ។

**តប. រដ្ឋមន្ត្រី**
**ប្រធាននាយកដ្ឋានវិវាទការងារ**

**ភ៊ុយ ទេពដារាវុធ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩